ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារពេលប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១២

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនលោក លោកស្រីទាំងអស់ ដែលជាម្ចាស់យានយន្តគ្រប់ប្រភេទមេត្តាជ្រាបថា ក្រសួងបានចេញប្រកាសលេខ ០៤២ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ និងសេចក្តីជូនដំណឹងលេខ ០០៦ សហវ.សជណ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ដែលមានរយៈពេល៥ខែ ចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ ។ រយៈពេលប្រមូលពន្ធ៥ខែនេះ វែងជាងពីឆ្នាំមុនៗ ដែលមានត្រឹមតែ៣ខែប៉ុណ្ណោះ ។ ការសម្រេចឲ្យមានរយៈពេលវែងដល់ទៅ៥ខែនេះ ពីព្រោះក្រសួងបានគិតគូរដល់ព្រឹត្តិការណ៍ជាតិធំៗនៅឆ្នាំ២០១២នេះ មានការប្រជុំកំពូលអាស៊ាន និងការប្រជុំអាស៊ានពាក់ព័ន្ធ ការបោះឆ្នោតឃុំ-សង្កាត់ជាដើម ។

ប៉ុន្តែ ដោយសង្កេតឃើញថា នៅពេលចុងក្រោយនេះ មានម្ចាស់យានយន្តគ្រប់ប្រភេទសម្រុកចូលមកធ្វើការបង់ពន្ធច្រើន បណ្តាលឱ្យមានការកកស្ទះក្នុងការផ្តល់សេវា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចពន្យារពេលការប្រមូលពន្ធនេះរហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ ដោយចាត់មន្ត្រីពន្ធដារឲ្យបំពេញការងារនៅថ្ងៃសៅរ៍និងថ្ងៃអាទិត្យ បន្ថែមទៀត ។

ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២តទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យ និងអនុវត្តការផាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ ចំពោះម្ចាស់យានយន្តទាំងឡាយណាដែលមានការយឺតយ៉ាវបង់ពន្ធក្រោយថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី ដែលជាម្ចាស់យានជំនិះគ្រប់ប្រភេទ ពិតជានឹងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចសារពើពន្ធបានល្អប្រសើរជាពុំខាន ។

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-រាជធានី
  "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់សាខាពន្ធដារខេត្ត-ខណ្ឌ
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com